## <u>សិក្ខាសាលាប្រចាំឆ្នាំស្តីអំពីការបង្កើនជីវភាពរស់នៅរបស់កសិករក្រីក្រនៅស្រុកត្រាំកក់តំណាក់កាល ទី ២</u>

នៅថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៩ សេដាក បានរៀបចំ សិក្ខាសាលាប្រចាំឆ្នាំមួយ ស្តីអំពីការបង្កើនជីវភាពរស់នៅរបស់កសិករក្រីក្រនៅស្រុកត្រាំកក់ តំណាក់កាលទី ២នៅស្រុកត្រាំកក់ ខេត្តតាកែវ ដោយមានអ្នកចូលរួមចំនួន ៧២ នាក់ ក្នុងនោះមានស្ត្រី ៩ នាក់។ សមាសភាពអ្នកចូលរួម រួមមានៈ ប្រធាននិងបុគ្គិកនៃមន្ទីរកសិកម្មខេត្តតាកែវ មន្ទីរកិច្ចការនារី មន្ទីរបរិស្ថាន អភិបាលស្រុកត្រាំកក់ ក្រុមប្រឹក្សាឃុំសង្កាត់មកពី ១៥ ឃុំ ការិយាល័យកសិកម្មស្រុក តំណាងកសិករ បុគ្គលិក សេដាក និងតំណាងអង្គកាក្រៅរដ្ឋាភិបាលជាច្រើនទៀតនៅក្នុងខេត្តតាកែវ។ អង្គសិក្ខាសាលា ទទួលបានការចូលរួមពីលោកស្រី នូ សូវន្និ អភិបាលរងខេត្តតាកែវ លោកកូបាយ៉ាស្សី យូគីហារូ អនុប្រធានប្រចាំប្រទេសកម្ពុជារបស់អង្គការ ចៃកា និងបណ្ឌិតយ៉ង សាំងកុមារ ប្រធានអង្គការសេដាក។ នៅក្នុងកំឡុងពេលសិក្ខាសាលា កសិករដែលទទួលបានជោគជ័យក្នុងការចិញ្ចឹមមាន់តាមគោលការធម្មជាតិ ប.វ.ស កសិដ្ឋានពហុប្រយោជន៏ និងសហគមន៏ស្រូវសរីរាង្គត្រូវបានអញ្ជើញឱ្យចែករំលែកនូវបទពិសោធន៏របស់គាត់ជូនដល់អង្គសិក្ខាសាលា។ សិក្ខាសាលនេះធ្វើឡើងក្នុងគោលបំណង ដើម្បីបង្ហាញពីសមិទ្ធិផល និងបទពិសោធន៏ របស់គំរោង បង្កើនជីវភាពរស់នៅរបស់កសិករក្រីក្រ ILFARM-TK តំណាក់កាលទី ២ ផ្តល់ឳកាសដល់កសិករឆ្នើមចែករំលែកនូវបទពិសោធន៏ផ្ទាល់របស់ពួកគេ និងកំនត់នូវអនុសាស្ត្រ និងយុទ្ធសាស្ត្រសម្រាប់និរន្តរភាពនៅបន្ទាប់ពីគម្រោងចប់ ឬដកចេញ។ សិក្ខាសាលានេះ ឧបត្ថម្ភដោយអង្គការ ចៃកា។

